អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងស្បៀងអាហារសម្រាប់ការអប់រំ

# ប័ណ្ណណែនាំអំពីរបៀបដឹកនាំ ការអានបែបសហការ

## ការស្រាវជ្រាវ

ទ្រឹស្តីវិទូខាងការអានឯកភាពគ្នាជាទូទៅថា មានវិធីសាស្ត្រសំខាន់ៗ៣ នៅក្នុងការអាន។

ហ្ក្រាហ្វូ-ហ្វូនិច (Grapho-phonic)
ស៊ីនថាកទិច (Syntactic)
ស៊ីម៉ានទិច (Semantic)

**ហ្ក្រាហ្វូ-ហ្វូនិច** (Grapho-phonic): ជាវិធីសាស្ត្រផ្តោតសំខាន់ទៅលើតួអក្សរ និងសូរនៃភាសា និងទំនាក់ទំនងរបស់វា (តួអក្សរនិងសូរ)។សូរត្រូវបានបង្ហាញតាមរយៈតួអក្សរដែលបូកបញ្ចូលគ្នាជាច្រើនយ៉ាងដើម្បីបង្កើតបានជាពាក្យ។

**ស៊ីនថាកទិច** (Syntactic): ទាក់ទងទៅនឹងរចនាសម្ព័ន្ធនៃភាសា។ វារួមមានទាំងវេយ្យករណ៍ និង របៀបដែលភាសាត្រូវបានប្រើក្នុងលក្ខខណ្ឌខុសៗគ្នា។ នៅពេលយើងធំឡើងយើងបានប្រើភាសាកំណើតរបស់យើងតាមរបៀបផ្សេងៗ ហើយយើងក៏បានចេះដឹង អំពីវិធីប្រើប្រាស់ភាសានេះ សព្វបែបសព្វយ៉ាង។ ជាឧទាហរណ៍៖ មនុស្សនិយាយរកគ្នាទៅវិញទៅមក ក្នុងមធ្យោបាយផ្សេងៗ អាស្រ័យលើទំនាក់ទំនង និងតម្លៃវប្បធម៌របស់ពួកគេ។

**ស៊ីម៉ានទិច** (Semantic): ទាក់ទងទៅនឹងអត្ថន័យ នៃអត្ថបទ។ យើងប្រើប្រាស់បទពិសោធដែលមានក្នុងពិភពលោក និងប្រធានបទដោយឡែកណាមួយដើម្បីបង្កើតអត្ថន័យ។ យើងផ្តោតអារម្មណ៍ផងដែរទៅលើរូបភាព និងអត្ថបទទាំងមូល ដើម្បីស្វែងយល់ន័យពីវា។ កត្តាទាំងនេះអាចពាក់ព័ន្ធនឹងការអានទៅមុខ ហើយ អានសារឡើងវិញ ដើម្បីបញ្ជាក់ន័យឲ្យកាន់តែច្បាស់។

## សេចក្តីណែនាំ សម្រាប់ការអានបែបសហការ:

- សិស្សទាំងអស់គួរតែអាចមើលឃើញអត្ថបទរៀងៗខ្លួន (សាលារៀននីមួយៗត្រូវបានផ្តល់ឲ្យជាមួយនឹងកន្ទេលបីដោយគម្រោង។ អ្នកអាចក្រាលកន្ទេលទាំងនេះនៅមុខថ្នាក់របស់អ្នក ឬនៅក្នុងទីធ្លាសាលាដើម្បីនាំសិស្សមកជិតងាយក្នុងការអានអត្ថបទ ។
- គ្រូបង្រៀនគួរតែអានវាដោយភាពស្ទាត់ជំនាញ និងការលើកដាក់សំឡេង ដើម្បីធ្វើឲ្យអត្ថបទមានភាពរស់រវើក និងមានអត្ថន័យ
- គ្រូបង្រៀនគួរតែធានាថា សិស្សបានយល់ដឹងអត្ថបទច្បាស់តាមរយៈការនិយាយអំពីវា ដែលភ្ជាប់ដោយរូបភាព និងសុំឲ្យសិស្សបញ្ចេញយោបល់ ។ល។
- គ្រូបង្រៀនត្រូវមានភាពច្បាស់លាស់ក្នុងការកំណត់វិធីសាស្ត្រត្រូវប្រើនៅកម្រិតមួយដែលសមរម្យ
- ថតចម្លងសេចក្តីណែនាំ
- ឆ្លើយឆ្លងជាមួយសិស្ស មួយទៅមួយមក (១:១)
- វិធីសាស្ត្រញែកសូរ - ឧទាហរណ៍: សំឡេងដើម, កម្លាយពាក្យ
- វិធីសាស្ត្រ ស៊ីម៉ានទិច - ឧទាហរណ៍: ពាក្យណាខ្លះដែលនឹងធ្វើឲ្យមានន័យថាតើពាក្យអាំងនោះមាននៅក្នុអត្ថបទពីមុនមកទេ

ថាតើពាក្យអាំងនោះមានទំនាក់ទំនងជាមួយពាក្យដែលយើងស្គាល់រួចហើយឬទេ ។ល។

❖ វិធីសាស្ត្រស៊ីនថាកទិច - ជាអ្វីមួយដែលត្រឹមត្រូវតាមក្បួនខ្នាតវេយ្យាករណ៍ ឬដែលយើងនិយាយឬទេ?

**<u>មានសំនួរជាច្រើនប្រភេទដែលអ្នកអាចប្រើដើម្បីជួយកុមារក្នុងការអានអត្ថបទ</u>**

| សំណួរ | វិធីសាស្ត្រសំខាន់ៗ |
|---|---|
| តើខ្ញុំអាចបន្លឺសូរវាបានឬអត់? | ហ្គ្រាហ្វូ-ហ្វូនិច (Grapho-phonic) |
| តើវាមានន័យឬទេ? | ស៊ីម៉ានទិច (Semantic) |
| តើវាដូចជាពាក្យអ្វី? | ហ្គ្រាហ្វូ-ហ្វូនិច (Grapho-phonic) |
| តើវាត្រឹមត្រូវឬទេ? | ស៊ីម៉ានទិច (Semantic) |
| តើខ្ញុំអាចបំបែកវាជាផ្នែកបានដែរឬទេ? | ហ្គ្រាហ្វូ-ហ្វូនិច (Grapho-phonic) |
| តើវាត្រូវនឹងរូបភាពនេះឬទេ? | ស៊ីម៉ានទិច (Semantic) |
| តើនេះជារបៀបដែលយើងគួរនិយាយឬទេ? | ស៊ីនថាកទិច (Syntactic) |
| តើវាស៊ីនិងពាក្យដ៏ទៃក្នុងអត្ថបទឬទេ? | ស៊ីម៉ានទិច (Semantic) |
| តើវាជាអ្វីមួយដែលខ្ញុំធ្លាប់ស្គាល់មែនទេ? | ស៊ីម៉ានទិច (Semantic) |

ការអានបែបសហការ

**<u>សូមចូលមើល(វីដេអូ)តាមវេបសាយខាងក្រោម :</u>**

https://drive.google.com/open?id=13b6JoMdPvQkmMafrllOemVohMzCrJ7h0
https://youtu.be/9NmzEAMXxBc



